# របាយការណ៍
# បូកសរុបលទ្ធផលសកម្មភាព
# នៃការអនុវត្តផែនការយុទ្ធសាស្រ្តបញ្រ្ជាបយេនឌ័រ រយៈពេល៥ឆ្នាំ (២០១១-២០១៦)

## I. ស្ថានភាពទូទៅ

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានកម្មវិធីនយោបាយ ច្បាប់ គោលនយោបាយ យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ «បន្តពង្រឹងស្ថានភាព និងតួនាទីដ៏សំខាន់នៅក្នុងសង្គម លើកស្ទួយសីលធម៌ និងតម្លៃស្ត្រីខ្មែរ លុបបំបាត់ទស្សនៈមើលស្រាលតួនាទីស្ត្រី សំដៅលើកកម្ពស់ការចូលរួមរបស់ស្ត្រី ឲ្យកាន់តែទូលំទូលាយ និងខ្លាំងក្លាថែមទៀត ក្នុងការកសាង និងការពារមាតុភូមិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការអនុវត្តលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ជាលទ្ធផលវិជ្ជមានរយៈពេល ២ទស្សវត្សនេះ ស្ថានភាពស្ត្រីនៅប្រទេសកម្ពុជា មានការវិវត្តន៍ឈានឡើង នូវចំនួនស្ត្រី ដែលមានសមត្ថភាពក្នុងការចូលរួមធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ដូចជា៖

**+ ស្ថាប័ននីតិបញ្ញត្តិ**

-ស្ថាប័នព្រឹទ្ធសភាឆ្នាំ២០១២ ស្ត្រីទទួលបានអសនៈចំនួន១៤,៧៥ភាគរយ (ស្ត្រី ០៩រូប លើចំនួន ៦១រូប)

-ស្ថាប័នរដ្ឋសភា ឆ្នាំ១៩៩៣ មានចំនួនអសនៈ ៦ភាគរយ ឆ្នាំ ២០១៣ កើនបានអសនៈដល់ ២០,៣៣ភាគរយ ។

**+ រាជរដ្ឋាភិបាល** ស្ត្រីមានតួនាទីសំខាន់ៗ

-ឧបនាយករដ្ឋមន្ត្រី ០១ រូប

-រដ្ឋមន្ត្រី ឆ្នាំ ២០០៨ មានចំនួន ៧,៤ភាគរយ ឆ្នាំ ២០១៣ កើនដល់ ១០,៧ភាគរយ

-រដ្ឋលេខាធិការ ឆ្នាំ ២០០៨ មានចំនួន ៨,០៨ភាគរយ ឆ្នាំ ២០១៣ កើនដល់ ២០,៥៤ភាគរយ

-អនុរដ្ឋលេខាធិការឆ្នាំ ២០០៨ មានចំនួន ១៦ភាគរយ ឆ្នាំ ២០១៣ កើនដល់ ១៧,៦០ភាគរយ ។

**+ ស្ថាប័នតុលាការ** សមាមាត្រស្ត្រីក៏មានការកើនឡើង ចាប់ពីឆ្នាំ២០០៨ ក៏ប៉ុន្តែស្ត្រីមានចំនួនតិចនៅគ្រប់កម្រិតនៃស្ថាប័ននេះ ។ ដោយឡែកស្ត្រី ជាសមាជិកគណៈមេធាវី (ឆ្នាំ២០១២ - ២០១៥) មានចំនួន ១៤,៨ភាគរយ ប៉ុណ្ណោះ ។

ក្រសួងមហាផ្ទៃ ក្រោមការដឹកនាំរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានចូលរួមអនុវត្តកម្មវិធីនយោបាយ ច្បាប់ពាក់ព័ន្ធនានា ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាព

អង់អាចដល់ស្ត្រី ក្រសួងមហាផ្ទៃ បានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងមានយន្តការធានាការអនុវត្ត ឲ្យទទួលបាននូវប្រសិទ្ធភាពខ្ពស់ ដែលមានខ្លឹមសាររួម ដូចខាងក្រោម៖

**យុទ្ធសាស្ត្រទី១៖** កាត់បន្ថយគម្លាតយេនឌ័រក្នុងរចនាសម្ព័ន្ធក្រសួងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

**យុទ្ធសាស្ត្រទី២៖** ពង្រឹងកិច្ចសហការប្រតិបត្តិការផ្ទៃក្នុងក្រសួងជាមួយដៃគូជាតិ និងអន្តរជាតិដើម្បីឈាន ទៅបញ្ជ្រាបយេនឌ័រឲ្យបានទូលំទូលាយទាំងក្នុងការអនុវត្តភារកិច្ចតាមស្ថាប័នទាំងក្នុងការផ្តល់សេវាសាធារណៈ ក្នុងគោលដៅ លើកកម្ពស់សមាភាពយេនឌ័រ និងលុបបំបាត់អំពើហិង្សាលើស្ត្រី គ្រប់រូបភាព ។

**យុទ្ធសាស្ត្រទី៣៖** សិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ វាយតម្លៃការអនុវត្តផែនការ និងគោលនយោបាយពាក់ព័ន្ធនានាសំដៅធ្វើឲ្យសម្រេចគោលដៅជាយុទ្ធសាស្ត្រ ក្នុងការលើកកម្ពស់សមភាពយេនឌ័ររបស់ក្រសួងមហាផ្ទៃ ។

## II. លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ

ដើម្បីធានាឲ្យការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទទួលបានប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ក្រសួងមហាផ្ទៃ បានបង្កើតក្រុមការងារយេនឌ័រ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ជាយន្តការសម្រាប់ជម្រុញការអនុវត្ត ។

**ក. <u>យុទ្ធសាស្ត្រទី១៖</u>** «កាត់បន្ថយគម្លាតយេនឌ័រក្នុងរចនាសម្ព័ន្ធក្រសួងពីថ្នាក់ជាតិ ដល់ ថ្នាក់ក្រោមជាតិ»

### ១.១ ការលើកកម្ពស់សមភាពយេនឌ័រ ក្នុងក្របខ័ណ្ឌក្រសួង

**+ ទិន្នន័យក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ឆ្នាំ ២០១១ - ២០១៦ ៖**

| ក្រសួងមហាផ្ទៃ | ក្របខណ្ឌឆ្នាំ២០១១ | | | ក្របខណ្ឌឆ្នាំ២០១៦ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ភាគរយ (%) | សរុប | ស្ត្រី | ភាគរយ (%) |
| សរុបរួម | ៩.៦២១ | ២.០៣៣ | ២១,១៣ | ៩.៨២២ | ២.៥៥២ | ២៥,៩៨ |
| ថ្នាក់ជាតិ | | | | ៨៣៩ | ១៦៦ | |
| ថ្នាក់ក្រោមជាតិ | | | | ៨.៩៨៣ | ២.៣៨៦ | |

**+ ទិន្នន័យក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ឆ្នាំ ២០១១ - ២០១៦ ៖**

| ក្រសួងមហាផ្ទៃ | ក្របខណ្ឌឆ្នាំ២០១១ | | | ក្របខណ្ឌឆ្នាំ២០១៦ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ភាគរយ (%) | សរុប | ស្ត្រី | ភាគរយ (%) |
| សរុបរួម | ២.១០០ | ១៨៥ | ៨,៨០ | ២.៤៧១ | ២៧៣ | ១១ |
| ថ្នាក់ជាតិ | | | | ៨៨១ | ១១១ | |
| ថ្នាក់ក្រោមជាតិ | | | | ១.៥៩០ | ១៦២ | |

**+ ទិន្នន័យក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឆ្នាំ ២០១១ - ២០១៦ ៖**

| ក្រសួងមហាផ្ទៃ | ក្របខណ្ឌឆ្នាំ២០១១ | | | ក្របខណ្ឌឆ្នាំ២០១៦ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ភាគរយ (%) | សរុប | ស្ត្រី | ភាគរយ (%) |
| សរុបរួម | ៥៦.៣៣៣ | ២.៦៣៧ | ៤,៦៨ | ៥៥.៧៦០ | ៣.២០៦ | ៥,៧៤ |
| ថ្នាក់ជាតិ | ១៥.៥៩៨ | ១.០០៥ | | ១៦.៨៣០ | ១.១៥៩ | |
| ថ្នាក់ក្រោមជាតិ | ៤០.៧៣៥ | ១.៦៣២ | | ៣៨.៩៣០ | ២.០៤៧ | |

## ១.១.១ ស្ត្រីមានតួនាទីសំខាន់ៗក្នុងរចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

### ១.១.១.១ ថ្នាក់ដឹកនាំក្រសួង

-រដ្ឋលេខាធិការ ០១រូប

-អនុរដ្ឋលេខាធិការ ០១រូប

## ១.១.២. ថ្នាក់ចាប់ពីប្រធានការិយាល័យ ឡើងដល់ អគ្គនាយក ឬ ថ្នាក់ស្មើ

### ១.១.២.១. រដ្ឋបាលស៊ីវិល

**ថ្នាក់ជាតិ:**

- អគ្គនាយក ឬ ថ្នាក់ស្មើ មានចំនួន ០៧ រូប មានស្រី០១ រូប (អនុប្រធានក្រុមប្រឹក្សានីតិកម្ម)
- អគ្គនាយករង ឬ ថ្នាក់ស្មើ មានចំនួន ៣៦ រូប មានស្រី០៤ រូប
- ប្រធាននាយកដ្ឋាន ឬ ថ្នាក់ស្មើ មានចំនួន ២២ រូប មានស្រី០១ រូប
- អនុប្រធាននាយកដ្ឋាន ឬ ថ្នាក់ស្មើ មានចំនួន១៣១ រូប មានស្រី១៦ រូប
- ប្រធានការិយាល័យ ឬ ថ្នាក់ស្មើ មានចំនួន ៨១ រូប មានស្រី១៦ រូប
- អនុប្រធានការិយាល័យ ឬ ថ្នាក់ស្មើ មានចំនួន ២០១ រូប មានស្រី៥២ រូប

**ថ្នាក់ក្រោមជាតិ ( រាជធានី ខេត្ត ) ( ក្រុង ស្រុក ខណ្ឌ )**

- អភិបាលនៃ គណៈអភិបាលរាជធានី ខេត្ត មានចំនួន ២៥ រូប មានស្រី ០០ រូប
- អភិបាលរង រាជធានី ខេត្ត មានចំនួន ១៤៩ រូប មានស្រី ២៧ រូប
- អភិបាល ក្រុង ស្រុក ខណ្ឌ មានចំនួន ១៩៧ រូប មានស្រី ០៦ រូប
- អភិបាលរង ក្រុង ស្រុក ខណ្ឌ មានចំនួន ៧២៦ រូប មានស្រី ១៨៨ រូប

**ថ្នាក់រដ្ឋបាលសាលារាជធានី ខេត្ត**

-នាយក មានចំនួន ២៥ រូប មានស្រី ០០ រូប

-នាយករង មានចំនួន ៧៨ រូប មានស្រី ១១ រូប

-ប្រធានការិយាល័យ មានចំនួន ៣៧៤ រូប មានស្រី ៧៦ រូប

-អនុប្រធានការិយាល័យ មានចំនួន ៦៥៣ រូប មានស្រី ២៥១ រូប

**ថ្នាក់រដ្ឋបាលសាលា ក្រុង ស្រុក ខណ្ឌ**

- នាយក មានចំនួន ១៦៥ រូប មានស្រី ១៥ រូប

- នាយករង មានចំនួន ២៥៤ រូប មានស្រី ៥៥ រូប

- ប្រធានការិយាល័យ មានចំនួន ៤៦៨ រូប មានស្រី ៩៥ រូប

- អនុប្រធានការិយាល័យ មានចំនួន ៧៤២ រូប មានស្រី ២៥៣ រូប

- ស្មៀន ឃុំ សង្កាត់ទូទាំងប្រទេស មានចំនួន ១៦៣៣ រូប មានស្រី ១៩៩ រូប ស្មើនឹង ១២,១៨ ភាគរយ ។

**<u>១.១.២.២. អគ្គនាយកដ្ឋានពន្ធនាគារ</u>**

| | | |
|---|---|---|
| -អគ្គនាយក | មានចំនួន ០១រូប | ស្រី០០រូប |
| -អគ្គនាយករង | មានចំនួន ១៥ រូប | ស្រី០៣រូប |
| -ប្រធាននាយកដ្ឋាន ឬ ថ្នាក់ស្មើ | មានចំនួន ០៥ រូប | ស្រី០០រូប |
| -អនុប្រធាន នាយកដ្ឋាន ឬ ថ្នាក់ស្មើ | មានចំនួន ៧១ រូប | ស្រី០៤រូប |
| -ប្រធានការិយាល័យ ឬ ថ្នាក់ស្មើ | មានចំនួន១២៩រូប | ស្រី០៨រូប |
| -អនុប្រធានការិយាល័យ ឬ ថ្នាក់ស្មើ | មានចំនួន១៣៣រូប | ស្រី០៩រូប |
| -ប្រធានផ្នែក ឬ ថ្នាក់ស្មើ | មានចំនួន១៩១រូប | ស្រី១៨រូប |
| -អនុប្រធានផ្នែក ឬ ថ្នាក់ស្មើ | មានចំនួន២៥១រូប | ស្រី២៥រូប |

* ក្នុងឆ្នាំ ២០១៦ ទិន្នន័យមន្ត្រីពន្ធនាគារជាស្ត្រីមានឋានន្តរសក្តិគិតចាប់ពីថ្នាក់អនុរក្សថ្នាក់លេខ៣ ដល់ ថ្នាក់ឧត្តមអគ្គានុរក្ស:

+ថ្នាក់ឧត្តមអគ្គានុរក្សរួមមាន:

- ឧត្តមអគ្គានុរក្សថ្នាក់លេខ១ មានចំនួន ០១នាក់
- ឧត្តមអគ្គានុរក្សថ្នាក់លេខ២ មានចំនួន ០៣នាក់

+ថ្នាក់វរអគ្គានុរក្សរួមមាន:

- វរអគ្គានុរក្សថ្នាក់លេខ១ មានចំនួន ១៣នាក់
- វរអគ្គានុរក្សថ្នាក់លេខ២ មានចំនួន ៣៩នាក់
- វរអគ្គានុរក្សថ្នាក់លេខ៣ មានចំនួន ៥២នាក់

+ថ្នាក់អគ្គានុរក្សរួមមាន:

- អគ្គានុរក្សថ្នាក់លេខ១ មានចំនួន ០៨នាក់
- អគ្គានុរក្សថ្នាក់លេខ២ មានចំនួន ២៣នាក់

- អគ្គានុរក្សថ្នាក់លេខ៣ មានចំនួន ០៨នាក់

- អគ្គានុរក្សថ្នាក់លេខ៤ មានចំនួន ១៧នាក់

+ថ្នាក់អនុរក្សរួមមាន:

- អនុរក្សថ្នាក់លេខ១ មានចំនួន ៥០នាក់

- អនុរក្សថ្នាក់លេខ២ មានចំនួន ៣២នាក់

- អនុរក្សថ្នាក់លេខ៣ មានចំនួន ៣២នាក់

១.១.២.៣. កម្លាំងនគរបាលជាតិ

ថ្នាក់ជាតិ:

- អគ្គនាយក មាន ០៧រូប ស្ត្រី ០១រូប ស្មើនឹង ១៤.២៨%
- អគ្គនាយករង មាន ៣៦រូប ស្ត្រី ០៤រូប ស្មើនឹង ១១.១១%
- ប្រធាននាយកដ្ឋាន និងថ្នាក់ស្មើ មាន ២២រូប ស្ត្រី ០១រូប ស្មើនឹង ៤.៥៤%
- អនុប្រធាននាយកដ្ឋាន និងថ្នាក់ស្មើ មាន ១៣១រូប ស្ត្រី ១៦រូប ស្មើនឹង ១២.២១%
- ប្រធានការិយាល័យ និងថ្នាក់ស្មើ មាន ៨១រូប ស្ត្រី ១៦រូប ស្មើនឹង ១៩.៧៥%
- អនុប្រធានការិយាល័យ និងថ្នាក់ស្មើ មាន ២០១រូប ស្ត្រី ៥២រូប ស្មើនឹង ២៥.៨៧%
- ប្រធានផ្នែក និងថ្នាក់ស្មើ មាន ២២រូប ស្ត្រី ០១រូប ស្មើនឹង ៤.៥៤%
- អនុប្រធានផ្នែក និងថ្នាក់ស្មើ មាន ១៣១រូប ស្ត្រី ១៦រូប ស្មើនឹង ១២.២១%

## ១.២. ស្ត្រីមានតួនាទីជាតំណាង តាមរយៈការបោះឆ្នោតសកល និងអសកល

១.២.១. ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

*** តួនាទីស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត៖**

- ឆ្នាំ ២០០៩ មានចំនួន ៣៨រូប លើចំនួនសរុប ៣៧៤រូប ស្មើនឹង ១០ ភាគរយ
- ឆ្នាំ ២០១៤ មានចំនួន ៥២រូប លើចំនួនសរុប ៣៩៣រូប ស្មើនឹង ១៣,២៣ភាគរយ

*** តួនាទីស្ត្រីជាសមាជិកក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ៖**

- ឆ្នាំ ២០០៩ មានចំនួន ៣៦៣រូប លើចំនួនសរុប ២៨៦១រូប ស្មើនឹង ១២,៦៨ ភាគរយ
- ឆ្នាំ ២០១៤ មានចំនួន ៤០៦រូប លើចំនួនសរុប ២៩៣១រូប ស្មើនឹង ១៣,៨៥ ភាគរយ

១.២.២. ក្រុមប្រឹក្សា ឃុំ សង្កាត់៖

-ឆ្នាំ ២០០២ មានប្រមាណ ៩,៤០ ភាគរយ

-ឆ្នាំ ២០០៧ មានប្រមាណ ១៥,១០ភាគរយ

-ឆ្នាំ ២០១២ មានប្រមាណ១៧,៧៨ភាគរយ

ស្ត្រីនៅតែមានតំណាងតិចក្នុងមុខតំណែងធ្វើសេចក្តីសម្រេច សំខាន់ៗ ដូចជា មេឃុំ ចៅសង្កាត់ មាន ៤,២២ ភាគរយ (៦៩ រូប) បុរស ៩៥,៧៨ ភាគរយជំទប់ទី១ មាន ១១,៥៧ ភាគរយ (១៨៩រូប) បុរសមាន ៨៨,៤៣ភាគរយ ជំទប់ទី២ មាន ៩,២៤ ភាគរយ (១៥១រូប) បុរស មាន ៩០,៧៦ ភាគរយ ។

អត្រាស្ត្រី ជាសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ មានចំនួនកើនឡើង ជាលំដាប់ បុរសនៅតែមានមុខតំណែង សំខាន់ៗ ក្នុងតួនាទីធ្វើសេចក្តីសម្រេច នៅថ្នាក់ ឃុំ សង្កាត់ ។

### ១.២.៣. ថ្នាក់ដឹកនាំភូមិ

ចំនួនភូមិទូទាំងប្រទេសមានចំនួន ៖

-អណត្តិទី ២ មានភូមិចំនួន១.៤០៨ភូមិ មានថ្នាក់ដឹកនាំសរុប ៤២.២៤៩រូប មានស្រី ៣០% ភាគរយ (១ភូមិ ៣ នាក់ មានប្រធាន ១រូប អនុប្រធាន១រូប និងជំនួយការ១រូប មានស្ត្រីម្នាក់ ជាមធ្យម) ។

-ឆ្នាំ២០១៦ មានភូមិចំនួន១៤.៣៨៣ភូមិ មានថ្នាក់ដឹកនាំសរុប ៤៣.១៤៨រូប មានស្រី១៤.៣៨៣រូប ស្មើនឹង ៣៣.៣៣ ភាគរយ (១ភូមិមាន ៣នាក់ មានស្ត្រីម្នាក់ជាមធ្យម) ។

## ១.៣. ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាព

ការអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស គឺជាការងារស្នូល ក្នុងការអនុវត្តភារកិច្ចទទួលបានជោគជ័យ ។ ក្រុមការងារយេនឌ័រទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពរយៈពេលវែង មធ្យម និងឆ្នាំ ការរៀបចំតួនាទី ភារកិច្ចគ្រប់អង្គភាពឲ្យឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

### ១.៣.១. ក្រុមការងារយេនឌ័រថ្នាក់ជាតិ

+ ក្រុមការងារយេនឌ័រក្រសួង បានសហការជាមួយអង្គការ UN-WOMEN សាលាអភិបាលកិច្ច និងក្រុមការងារយេនឌ័រថ្នាក់ជាតិ រៀបចំវគ្គបង្កើនចំណេះដឹងយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ពង្រឹងតួនាទី និងភារកិច្ចមន្ត្រីបង្គោលយេនឌ័រ សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការស្ត្រីនិងភាពជាអ្នកដឹកនាំ ពង្រឹងសមត្ថភាពយេនឌ័រ និងគណនេយ្យភាពសង្គម សមភាពយេនឌ័រ និងទេសន្តរប្រវេសន៍ បង្កើនសមត្ថភាពស្ត្រីដើម្បីឆ្លើយតបនឹងតម្រូវការជាអាទិភាពក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ សមាសភាពចូលរួម មានសមាជិកក្រុមការងារយេនឌ័រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួនសរុប ៥០២រូប មានស្ត្រី ៣៣៥រូប ។

+ **អគ្គស្នងការដ្ឋាននគរបាលជាតិ** និងបណ្តាញក្រុមការងារយេនឌ័រស្នងការដ្ឋាននគរបាលរាជធានី ខេត្ត បានសហការជាមួយកម្មវិធីAATTIP និងអង្គការសកម្មភាពដើម្បីកុមារ និងមានការគាំទ្រគម្រោង ពីថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញដូចជា៖ ការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

សមភាពយេនឌ័រនិងបង្កើនការចូលរួមរបស់នគរបាលជាស្ត្រីនៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ជំនាញស៊ើបអង្កេតអំពើជួញដូរមនុស្ស គោលនយោបាយភូមិឃុំមានសុវត្ថិភាព ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សិក្ខាសាលាថ្នាក់ជាតិពិគ្រោះយោបល់ ស្តីពីសមភាពយេនឌ័រក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជាសរុបបានចំនួន៧៩វគ្គមានសិក្ខាកាមចូលរួម ៤.១៥៦រូប មានស្ត្រី ១.២១៦រូប មានរាជធានីភ្នំពេញ ខេត្តសៀមរាប កំពង់ឆ្នាំង បាត់ដំបង មណ្ឌលគិរី កណ្តាល តាកែវ កំពង់ធំ កំពង់ស្ពឺ កំពត កែប ព្រះវិហារ ប៉ៃលិន កោះកុង ពោធិសាត់ ឧត្តរមានជ័យ រតនគិរី ស្ទឹងត្រែង និងវរៈការពារព្រំដែន ។

+ **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ជាអគ្គនាយកដ្ឋានទើបបង្កើតឡើងនៅឆ្នាំ២០១៥ បានយកចិត្តទុកដាក់បង្កើតក្រុមការងារយេនឌ័រគ្រប់កម្រិតអង្គភាពចំណុះអគ្គនាយកដ្ឋាន និងបានរៀបចំយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ គោលនយោបាយ ផែនការសកម្មភាព និងការអនុវត្តភារកិច្ចជំនាញនីមួយៗ និងបើកវគ្គបំប៉នសមត្ថភាពមន្ត្រីដូចជា៖ វគ្គបំប៉នសមត្ថភាពទស្សនៈយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីជាស្ត្រី ស្តីពីភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីក្នុងការអនុវត្តច្បាប់ វគ្គស្តីពីការសម្របសម្រួលពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ ។

អគ្គនាយកដ្ឋានបានបញ្ជូនមន្ត្រីចូលរួមវគ្គសំខាន់ៗដូចជា៖ វគ្គស្តីពីតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជា ពត៌មានវិទ្យា ជំនាញរដ្ឋបាលជំនាន់ទី៩ បណ្តុះបណ្តាលបឋមក្របខណ្ឌស៊ីវិលថ្មី វិក្រិត្យការមន្ត្រីជាន់ខ្ពស់និងមធ្យម ។ បានបញ្ជូនទៅសិក្សាថ្នាក់បរិញ្ញាប័ត្រ ភាសាអង់គ្លេស និងបានបញ្ជូនទៅសិក្សានៅក្រៅប្រទេស សរុបសិក្ខាកាមចំនួន ១៤៥រូប មានស្ត្រី ១១៤រូប ។

+ **អគ្គនាយកដ្ឋានពន្ធនាគារ** បានរៀបចំបណ្តាញក្រុមការងារយេនឌ័រតាម មណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ចំណុះអគ្គនាយកដ្ឋាន ចំនួន ២៧ក្រុមការងារយេនឌ័រ ។ ក្រុមការងារយេនឌ័រ បានជ្រើសតាំងមន្ត្រីបង្គោលការងារយេនឌ័រ សម្រាប់បណ្តុះបណ្តាល និងផ្សព្វផ្សាយបន្តអំពីចំណេះដឹងទស្សនៈនិងគោលគំនិតយេនឌ័រ ការបញ្ជ្រាបក្នុងគោលនយោបាយ ផែនការសកម្មភាព និងបានបញ្ជ្រាបយុទ្ធសាស្ត្រយេនឌ័ររបស់ក្រសួង ក្នុងការអនុវត្តតាមជំនាញនីមួយៗ និងបង្កើនការអប់រំទណ្ឌិត (ស្ត្រី និងកុមារ) ។ ក្រុមការងារយេនឌ័រ បានសហការជាមួយអង្គការជាតិ ដៃគូអភិវឌ្ឍ ស្ថាប័នពាក់ព័ន្ធ សំដៅលើកកម្ពស់សេវាថែទាំសុខភាព ការផ្តល់ឱសថ ការពិនិត្យព្យាបាលជម្ងឺ ការផ្តល់អាហារូបត្ថម្ភ សេវាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនទណ្ឌិតបានទទួលការស្តារនីតិសម្បទា ជនជាប់ចោទ ។ល។

+ **បណ្ឌិត្យសភានគរបាលកម្ពុជា** បានបង្កើតបណ្តាញក្រុមការងារយេនឌ័រ តាមនាយកដ្ឋាន និងអង្គភាពចំណុះមានឋានៈស្មើដោយមានការពង្រឹងសមត្ថភាពគ្រូបង្គោលការងារយេនឌ័រដើម្បីបញ្ជ្រាបគោលគំនិតទស្សនៈយេនឌ័រ នៅក្នុងកម្មវិធីសិក្សាគ្រប់វគ្គរយៈពេលវែង មធ្យម និងរយៈពេលខ្លី គ្រប់កម្រិតជូនមន្ត្រីនគរបាលជាតិដូចជា៖ ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ បរិញ្ញាប័ត្រពិសេស ការស្រាវជ្រាវនគរបាលជាតិ ជំនាញនគរបាល និងពន្ធនាគារ សរុបបាន ៨៤វគ្គ មានសិក្ខាកាមចំនួន ៧.៤៤៣រូប មានស្ត្រី ៤០២រូប ។

+ **អគ្គនាយកដ្ឋានរដ្ឋបាល** ការកសាងសមត្ថភាពមន្ត្រីរាជការស៊ីវិល ជាការងារចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពការងារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ក្រុមការងារយេនឌ័រ បានបញ្ជ្រាបយុទ្ធសាស្ត្រយេនឌ័រ របស់ក្រសួង លើការដឹកនាំការអនុវត្តភារកិច្ច និងបានបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទៅសិក្សានៅសាលាភូមិន្ទរដ្ឋបាល ។ ក្រុមការងារយេនឌ័រ បានសហការជាមួយអង្គការដៃគូអភិវឌ្ឍន៍ លេខាធិការដ្ឋាន គ.ជ.អ.ប អនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ បានរៀបចំវគ្គបណ្តុះបណ្តាល៖ ភាពជាអ្នកដឹកនាំ

បច្ចេកទេសរដ្ឋបាល ការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ បណ្តុះបណ្តាលគ្រូបង្គោលស្តីពីការរៀបចំគម្រោងក្រុង ស្រុក ខណ្ឌស្តីពីការគ្រប់គ្រងទិន្នន័យតាមCritical Thinking ភាពជាអ្នកដឹកនាំបែបផ្លាស់ប្តូរទម្រង់ និងបានបញ្ជូនមន្ត្រីរដ្ឋបាលស៊ីវិល ទៅចូលរួមសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ការងារ ទៅតាមស្ថាប័នផ្សេងៗ សរុបបាន១៩វគ្គ មានសិក្ខាកាម ៦២១រូប មានស្ត្រី ១៣៤រូប ។

+ **អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ** ក្រុមការងារយេនឌ័រ បានរៀបចំផែនការយុទ្ធសាស្ត្រយេនឌ័រ របស់អគ្គនាយកដ្ឋាន នឹងបានធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបយេនឌ័រទៅក្នុងការរៀបចំតួនាទី និងភារកិច្ចរបស់ថ្នាក់នាយកដ្ឋាន ឬ ថ្នាក់ស្មើ និងបានចូលរួមសហការជាមួយអង្គការ HEDC អន្តរជាតិ ក្នុងការបើកវគ្គបណ្តុះបណ្តាលចំនួន០៥វគ្គ ដើម្បីបង្កើនសមត្ថភាព ការយល់ដឹងពីច្បាប់ សិទ្ធមនុស្ស ការអប់រំទូទៅ ផ្នត់គំនិត ការធ្វើផែនការយុទ្ធសាស្ត្រ ពាក់ព័ន្ធជំនាញទូទៅ និងបង្កើនចំណេះដឹងទូទៅជាភាសាអង់គ្លេស ដែលមានសិក្ខាកាមចូលរួមចំនួន ៣៧៩រូប មានស្ត្រី ១៥៩រូប និងមានការចូលរួមពីបណ្តាអគ្គនាយកដ្ឋាន ចំនួន ០៧ ចំណុះក្រសួងមហាផ្ទៃ ។

+ **អគ្គាធិការដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.៣ ក្រុមប្រឹក្សានីតិកម្ម អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍** ក្រុមការងារយេនឌ័របានយកចិត្តទុកដាក់ ផ្សព្វផ្សាយយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួង និងពង្រឹងសមត្ថភាពមន្ត្រីអំពីទស្សនៈយេនឌ័រនិងការបញ្ជ្រាបយេនឌ័រ តាមកិច្ចប្រជុំ ប្រចាំត្រីមាស ឆមាស និងឆ្នាំ និងបានបញ្ចូលមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល អង្គភាពផ្សេង ឬ ស្ថាប័នផ្សេង ដើម្បីបង្កើនសមត្ថភាពយល់ដឹងពីសមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ច្បាប់ ផែនការសកម្មភាព ។ល។ សរុបសិក្ខាកាម ចូលរួម ១៦០រូប មាន ស្ត្រី ៣០រូបមានអគ្គនាយកដ្ឋាន សវនកម្មផ្ទៃក្នុង អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.៣ អគ្គាធិការដ្ឋាន អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ។

### ១.៣.២. ក្រុមការងារយេនឌ័រ ថ្នាក់ក្រោមជាតិ ( សាលារាជធានី ខេត្ត )

អនុវត្តតាមសេចក្តីណែនាំ ស្តីពីការបង្កើតក្រុមការងារយេនឌ័រនៅថ្នាក់ក្រោមជាតិ អង្គភាពចំណុះក្រសួងមហាផ្ទៃ ។ រាជធានី-ខេត្ត ទាំង២៥ បានរៀបចំបង្កើតក្រុមការងារយេនឌ័រ នៅរាជធានី-ខេត្ត ដោយមានឯកឧត្តមអភិបាលរាជធានី-ខេត្ត មួយចំនួនជាប្រធាន និងមានខេត្តមួយចំនួន លោកជំទាវអភិបាលរងខេត្ត ជាប្រធាន និងមានអនុប្រធាន សមាជិក ជាមន្ត្រីជំនាញរបស់ការិយាល័យ និងស្រុក ក្រុងចំណុះក្រសួងមហាផ្ទៃ ។ ដោយឡែកស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងពន្ធនាគារខេត្ត បានបង្កើតក្រុមការងារដោយឡែក ជាបណ្តាញក្រុមការងាររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានពន្ធនាគារ ។ ក្រុមការងារយេនឌ័រទាំង ០២ នេះបានសហការអនុវត្តភារកិច្ច ជាមួយក្រុមការងារយេនឌ័ររបស់សាលារាជធានី-ខេត្ត ។ ក្រុមការងារយេនឌ័របានខិតខំបំពេញភារកិច្ច ដោយសហការជាមួយមន្ត្រីជំនាញ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមាររាជធានី ខេត្ត អង្គការជាតិ អន្តរជាតិ ដែលមានកម្មវិធីលើកកម្ពស់សមភាពយេនឌ័រ មានដូចខាងក្រោម ៖

១. ការពង្រឹងសមត្ថភាព អំពីទស្សនៈយេនឌ័រ និងបញ្ជ្រាបយុទ្ធសាស្ត្រយេនឌ័រក្រសួងមហាផ្ទៃ នៅក្នុងផែនការអភិវឌ្ឍន៍របស់ខេត្ត សមធម៌សង្គម និងបរិយាប័ន្ន នៅក្នុងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពីឆ្នាំ២០១៦-២០១៨ និងការអនុវត្តផែនការបញ្ជ្រាបយេនឌ័រ នៅក្នុងសេចក្តីណែនាំបច្ចេកទេស ស្តីពីការកសាងកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ។

២. សហការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ១០ឆ្នាំ(២០១០-២០១៩) មានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាច ដល់ស្ត្រីនៅថ្នាក់ក្រោមជាតិដោយផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍សមត្ថភាព និងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចការនយោបាយ និងកិច្ចអភិវឌ្ឍន៍របស់មូលដ្ឋានដែលមានសកម្មភាពដូចខាងក្រោម ៖

-ការបណ្តុះបណ្តាល ស្តីពីគោលគំនិតទស្សនៈយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ វគ្គស្តីពី ស្ត្រី និងភាពជាអ្នកដឹកនាំ ។ សមាសភាពជាក្រុមប្រឹក្សា ស្រុក ក្រុង និងអភិបាលរង ស្រុក ក្រុង ជាស្ត្រី ១៣៣ រូប។ មានខេត្តក្រចេះ កំពង់ចាម កំពង់ឆ្នាំង បាត់ដំបង ប៉ៃលិន និងព្រះវិហារ ។

-ការពង្រឹងសមត្ថភាពស្ត្រី ជាក្រុមប្រឹក្សាថ្នាក់ខេត្ត ក្រុង ស្រុក តាមរយៈសិក្ខាសាលា ជាសេរី បាន០៣លើក សរុបអ្នកចូលរួម ៤២២ រូប ។

-វគ្គបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់ផ្សព្វផ្សាយបន្ត អំពី ការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្នសមាសភាពថ្នាក់ដឹកនាំ បុរស និង ស្រី ទាំង ២៥ រាជធានី ខេត្ត មានចំនួន ១២៥ រូប មានស្រី ៧៥ រូប ។

-សិក្ខាសាលា ពង្រឹងសមត្ថភាពស្ត្រី ថ្នាក់តំបន់ ស្តីពី យេនឌ័រ និង ជំនាញ តស៊ូ មតិសម្រាប់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ ថ្នាក់ ខេត្ត មានចំនួន ១១០ រូប មានស្រី ៨៦ រូប ។

-វេទិកានៅថ្នាក់ខេត្ត ដើម្បីកំណត់បញ្ហាក្នុងការអនុវត្តតាមមុខងារព្រមទាំងពិភាក្សារកដំណោះស្រាយបញ្ហា ចំនួន ១៦ ខេត្ត ។ សមាសភាពជាស្ត្រី ក្រុមប្រឹក្សា ខេត្ត និង អភិបាលរងខេត្ត ចំនួន ៣៧១ រូប ។

-វេទិកាថ្នាក់ស្រុក ដើម្បីកំណត់បញ្ហាប្រឈមជាអទិភាព និង ដោះស្រាយបញ្ហាពាក់ព័ន្ធ ក្នុងការអនុវត្តមុខងារ ចំនួន ១៥ ខេត្ត ។ សមាសភាពជាមន្ត្រីទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់ សរុប ចំនួន១.០២៦ រូប ។

* **<u>យុទ្ធសាស្ត្រទី២៖</u>** «ពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុងក្រសួង និងជាមួយដៃគូជាតិ អន្តរជាតិ » ដើម្បីឈានទៅបញ្ជ្រាប យេនឌ័រឲ្យបានទូលំទូលាយទាំងក្នុងការអនុវត្តភារកិច្ចតាមស្ថាប័ន ទាំងការផ្តល់សេវាសាធារណៈក្នុងគោលដៅលើកកម្ពស់សមភាពយេនឌ័រ និងលប់បំបាត់អំពើហិង្សាលើស្ត្រីគ្រប់រូបភាព៖

## ២.១. ការរៀបចំអបអរសាទរទិវាអន្តរជាតិនារី ៨មីនា

ប្រធានបទឆ្នាំនីមួយៗ មាន ៖

\+ ឆ្នាំ ២០១៣ «សិទ្ធស្មើគ្នា ឱកាសដូចគ្នា ដើម្បីពន្លឿនកិច្ចអភិវឌ្ឍន៍»

\+ ឆ្នាំ ២០១៤ «សមភាពនៃការអប់រំ មានសារសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សង្គម»

\+ ឆ្នាំ ២០១៥ «ដំណើរឆ្ពោះទៅមុខ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥»

\+ ឆ្នាំ ២០១៦ «វិនិយោគលើ សមភាពយេនឌ័រ ដើម្បីអភិវឌ្ឍន៍ប្រកបដោយចិរភាព»

### <u>២.១.១. ក្រុមការងារយេនឌ័រថ្នាក់ជាតិ</u>

ក្រុមការងារយេនឌ័រថ្នាក់ជាតិ ដោយមានការឧបត្ថម្ភគាំទ្រសកម្មភាពថ្នាក់ដឹកនាំក្រសួងមហាផ្ទៃជាពិសេស **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានរៀបចំៈ

- មិទ្ទិញនៅទីស្ដីការក្រសួង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ**
- ពិធីសំណេះសំណាលនៅតាមបណ្ដាអង្គភាពចំណុះក្រសួងមហាផ្ទៃ ។

សរុបសមាជិកចូលរួមចំនួន ៣.៣៤៥រូប មានស្ត្រី១.៦៦៩រូប ថវិកាគាំទ្រកម្មវិធីមិទ្ទិញ ក្រសួងរៀបចំ និងថវិកាចំនួន ៦៨.៣៤៤.០០០រៀល មានអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អន្តោប្រវេសន៍ ពន្ធនាគារ កស្តុការ និងហិរញ្ញវត្ថុ សវនកម្មផ្ទៃក្នុង បណ្ឌិត្យសភានគរបាលកម្ពុជា អគ្គាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋានអាជ្ញាធរប្រឆាំងគ្រឿងញៀន ។

ក្រសួងមហាផ្ទៃ បានចាត់តាំងស្ត្រី ជាថ្នាក់ដឹកនាំ ចូលរួម៖

- ជាគណៈប្រតិភូ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដឹកនាំដោយ **លោកជំទាវ រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី** ចូលថ្វាយព្រះពរ **សម្ដេចមហាក្សត្រី នរោត្តមមុនីនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** ក្នុងឱកាសចំរើនព្រះជន្ម ។
- ជាគណៈប្រតិភូអន្តរក្រសួងចូលជួបសម្ដែងការគួរសម បង្ហាញពីវឌ្ឍនភាពរបស់ស្ត្រី ក្នុងឱកាសទិវាអន្តរជាតិនារី៨មិនា ជាមួយ ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានចំនួន ០៥លើក ។
- ជាគណៈប្រតិភូក្រសួងមហាផ្ទៃ ចូលរួមជាកិត្តិយស ជាសមាជិកក្នុងមិទ្ទិញអបអរសាទរទិវាអន្តរជាតិ៨មិនា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** បានចំនួន ០៥លើក ។

### ២.១.២. ក្រុមការងារយេនឌ័រថ្នាក់សាលារាជធានី ខេត្ត

បានសហការជាមួយមន្ទីរជំនាញជុំវិញខេត្ត អង្គការជាតិ អន្តរជាតិ ក្រុមហ៊ុន សប្បុរសជន និងដោយមានការគាំទ្រទាំងសម្ភារៈ ថវិកាពីថ្នាក់ដឹកនាំរាជធានី-ខេត្ត ក្រុមការងារបានចាត់តាំងការផ្សព្វផ្សាយខ្លឹមសារទៅតាមប្រធានបទប្រចាំឆ្នាំផ្សារភ្ជាប់នឹងការវិវត្តស្ថានភាពស្ត្រី តាមរយៈការរៀបចំមិទ្ទិញនៅថ្នាក់ខេត្ត ពិធីសំណេះសំណាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មួយចំនួន សមាសភាពចូលរួមជាមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ សមាជិកសរុបចំនួន ១៩.២៨៧រូប ស្ត្រី៨.១៦៩រូប ការឧបត្ថម្ភកម្មវិធីមានសារ៉ុង៣.២២៥សារ៉ុង ក្រម៉ា១.៧៨៥ក្រម៉ា ថវិកាប្រាក់រៀល ២៤៨.៧៧០.៥០០រៀល ប្រាក់ដុល្លា២.៤៤៧ដុល្លាអាមេរិច មានខេត្តបាត់ដំបង ពោធិ៍សាត់ កណ្ដាល ស្វាយរៀង កោះកុង កំពង់ធំ និងមានខេត្តមួយចំនួន បង្កលក្ខណៈ ជូនមន្ត្រីនារី ទៅកំសាន្តនៅរមនីយដ្ឋាន នានា ។

## ២.២. ការអប់រំផ្សព្វផ្សាយ

ក្រុមការងារយេនឌ័រទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្រោមឱវាទក្រសួងមហាផ្ទៃបានសហការជាមួយស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ អង្គការដៃគូ អាជ្ញាធរមូលដ្ឋាន បានផ្សព្វផ្សាយ៖ អនុសញ្ញាស្ដីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) សេចក្ដីអង្កេតសន្និដ្ឋាន៥២ចំណុច អនុសាសន៍ដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ**

**ព្រះរាជាណាចក្រកម្ពុជា** ជាអនុប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ថ្លែងក្នុងឱកាសសន្និបាតបូកសរុបការងារ និងលើកផែនការសកម្មភាពប្រចាំឆ្នាំ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងឱកាសសន្និបាតបូកសរុបការងារប្រចាំឆ្នាំ ច្បាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស យុត្តិធម៌អនីតិជន ឪពុកម្តាយគំរូ ការធ្វើចំណាកស្រុកដោយខុសច្បាប់ កលល្បិចជនល្មើស និងផលប៉ះពាល់ដល់ស្ត្រីនិងកុមារ គោលនយោបាយភូមិឃុំមានសុវត្ថិភាព វេទិកាសាធារណៈរវាងនគរបាលនិងសហ-គមន៍ ការលើកកម្ពស់សេវាសង្គម បញ្ហាប្រជាជន និងការអភិវឌ្ឍន៍សុខភាពបន្តពូជ ការយល់ដឹងអំពីគ្រោះថ្នាក់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀនសម្រាប់ស្ត្រីជាមេផ្ទះ សរុបសមាជិកចូលរួមចំនួន ៨.៩០៥រូប មានស្ត្រី៥.៦៥០រូបមានអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងបណ្តាញក្រុមការងារយេនឌ័រអគ្គស្នងការដ្ឋាននគរបាលជាតិ មានខេត្តកំពត ពោធិ៍សាត់ មណ្ឌលគិរី ព្រៃវែង បាត់ដំបង រតនគិរី ឧត្តរមានជ័យ កំពង់ចាម ស្វាយរៀង និងកោះកុង ។

### ២.៣. កិច្ចសហការប្រតិបត្តិការ

<u>២.៣.១. ក្រុមការងារយេនឌ័រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សមាគមនានា អនុវត្តសកម្មភាពដូចខាងក្រោម ៖</u>

+ ផែនការសកម្មភាព និង**ព្រះរាជអនុសាសន៍ សម្តេចមហាក្សត្រី នរោត្តមមុនីនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះប្រធានកិត្តិយស** និងអនុសាសន៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា** អនុប្រធានកិត្តិយស ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

+ ផែនការសកម្មភាព និងអនុសាសន៍ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកិត្តិយសគណៈកម្មាធិការជាតិ លើកកម្ពស់ សីលធម៌ សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ ។

+ ផែនការសកម្មភាពជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ។

+ ក្រុមការងារបច្ចេកទេសយេនឌ័រ អន្តរក្រសួង

+ ក្រុមការងារមហាអនុតំបន់មេគង្គប្រឆាំងនឹងការជួញដូរមនុស្ស

+ គណៈកម្មាធិការអន្តរក្រសួង សម្រាប់ដឹកនាំត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ ឆ្នាំ ២០១៥ - ២០២០ ។

+ អគ្គនាយកដ្ឋានពន្ធនាគារ បានសហការជាមួយ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំយុវជននិងកីឡា គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ(ICRC) អង្គការសម្ព័ន្ធមេត្រី(PEC) អង្គការការីតាស(CARITAS) អង្គការស៊ីប៉ា(SIPAR) អង្គការមិត្តសំឡាញ់ អង្គការម្លប់តាប៉ាង អង្គការជីវិតនៃកម្ពុជា(TLC) អង្គការអិលណូដូ (ILNODO) អង្គការសុខភាពផ្លូវចិត្ត(TPO) អនុវត្តកម្មវិធី អប់រំសីលធម៌ ចិត្តសាស្ត្រ ចំណេះដឹងទូទៅ ភាសាអង់គ្លេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ទណ្ឌិត និងជនជាប់ឃុំ ។

+ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រុមការងារយេនឌ័រស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយកម្មវិធី AAPTIP កម្មវិធី APLE របស់អង្គការសកម្មភាពដើម្បីកុមារ អង្គការទស្សនៈពិភពលោក អង្គការយូនីសេហ្វ បើកវគ្គបំប៉នសមត្ថភាព ចំណេះដឹងយេនឌ័រ និងការងារជំនាញ យេនឌ័រនិងច្បាប់ពាក់ព័ន្ធនិងការជួញដូរមនុស្ស ផ្សព្វផ្សាយបង្កើនការយល់ដឹងពីច្បាប់ពាក់ព័ន្ធ និងអនុសញ្ញាCEDAW ការធ្វើចំណាកស្រុក ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ។ល។ នៅខេត្តបាត់ដំបង កំពង់ឆ្នាំង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ ព្រះសីហនុ ប៉ៃលិន និងព្រះវិហារ ។

+ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ បានសហការជាមួយអង្គការដៃគូ រៀបចំវគ្គពង្រឹងសមត្ថភាព ពីភាពជាអ្នកដឹកនាំបែបផ្លាស់ប្តូរទម្រង់ វគ្គស្តីពីគន្លឹះដើម្បីជោគជ័យផ្ទាល់ខ្លួននិងភាពជាអ្នកដឹកនាំ ។

**២.៤. ការងារសហគមន៍របស់ក្រុមការងារយេនឌ័រ**

ដោយមានការគាំទ្រឧបត្ថម្ភទាំងថវិកា សម្ភារៈ ពីថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន ឬ ថ្នាក់ស្មើ និងមានការសហការពីក្រុមការងារយេនឌ័រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានកម្មវិធីសួរសុខទុក្ខមន្ត្រីរាជការនគរបាលជាតិ ដែលមានជម្ងឺសម្រាកនៅមន្ទីរពេទ្យ គ្រោះថ្នាក់ដោយយថាហេតុ សម្រាកលំហែមាតុភាព មន្ត្រីបាត់បង់សមត្ថភាពការងារ មន្ត្រីចូលនិវត្តន៍ និងគ្រួសារមន្ត្រីរាជការ នគរបាលដែលទទួលមរណភាព ដោយជួយឧបត្ថម្ភជាថវិកា សម្ភារៈ និងគ្រឿងឧបភោគបរិភោគ ដូចមានខាងក្រោម ៖

+ **លោកជំទាវ ជូ ប៊ុនអេង និងក្រុមការងារយេនឌ័រ** ឧបត្ថម្ភថវិកាចំនួន ១៤.៩៨៣.០០០រៀល

+ **លោកជំទាវ យក់ សុខា និងក្រុមការងារយេនឌ័រអគ្គស្នងការដ្ឋាននគរបាលជាតិ** ឧបត្ថម្ភថវិកាចំនួន ៣៤.៤០៦.០០០ រៀល និង៨០០ដុល្លាអាមេរិច

+ **លោកជំទាវ ថន សុវណ្ណច័ន្ទខេម៉ា និងក្រុមការងារយេនឌ័របណ្ឌិត្យសភានគរកម្ពុជា** ឧបត្ថម្ភថវិកា ១.០៨០.០០០រៀល

+ **លោកជំទាវ អ៊ុំ លក្ខិណា និងក្រុមការងារយេនឌ័រអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ** ឧបត្ថម្ភថវិកា ២.៤០០.០០០ រៀល

+ **លោកជំទាវ ឱុច ដាណា និងក្រុមការងារយេនឌ័រអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ឧបត្ថម្ភថវិកា ៣.០០០.០០០រៀល មួកសុវត្ថិភាពចំនួន ២១មួក និងបានចូលរួមជាមួយកាកបទក្រហមកម្ពុជាចំនួន ៥.៥០០ដុល្លាអាមេរិច ។

+ **លោកស្រី ឈឹម សិទ្ធបុណ្យរិទ្ធ** និងក្រុមការងារយេនឌ័រអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន ឧបត្ថម្ភថវិកា ២.១០០.០០០រៀល ។

**គ. <u>យុទ្ធសាស្ត្រទី៣</u>៖** «សិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ វាយតម្លៃ ការអនុវត្តផែនការ និងគោលនយោបាយពាក់ព័ន្ធនានាសំដៅធ្វើឲ្យសម្រេចគោលដៅជាយុទ្ធសាស្ត្រក្នុងការលើកកម្ពស់សមភាពយេនឌ័ររបស់ក្រសួងមហាផ្ទៃ»

**៣.១. កិច្ចប្រជុំ:**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** ប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានដឹកនាំគណៈប្រតិភូអន្តរក្រសួង ពិនិត្យលើការអនុវត្តអនុសញ្ញាCEDAW សេចក្តីអង្កេតសន្និដ្ឋាន ៥២ចំណុច អនុសាសន៍ ដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** អនុប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងអនុសាសន៍ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់

សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងពិនិត្យលើការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងមហាផ្ទៃ នៅតាមបណ្តាខេត្ត ។

+ បានចាត់តាំងសមាជិក សមាជិកាក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃចំនួន០២រូប ចូលរួមជាគណៈប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ពិនិត្យ និងវាយតម្លៃការអនុវត្តអនុសញ្ញាCEDAW និងច្បាប់ពាក់ព័ន្ធ និងគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ នៅតាមបណ្តាខេត្តមួយចំនួន ។

+ ចូលរួមសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ លើការបញ្ជ្រាបយេនឌ័រជាមួយអន្តរក្រសួង អង្គការ UN-WOMEN បានចំនួន០៤លើក រៀបចំដោយក្រសួងកិច្ចការនារី ។

+ ប្រជុំពិនិត្យលើការអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងមហាផ្ទៃ ប្រចាំត្រីមាស ឆមាស និងឆ្នាំ

+ ពិភាក្សាលើរបាយការណ៍ឆ្នាំ និងលើកទិសដៅអនុវត្តឆ្នាំបន្ត

+ ពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ ស្តីពី លទ្ធផលសកម្មភាពការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ពី ឆ្នាំ ២០១១-២០១៥ - (២០១៦)

+ ពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រ ដើម្បីសមភាពយេនឌ័រ ពីឆ្នាំ ២០១៦ - ២០២០

+ ក្រុមការងារយេនឌ័របណ្តាថ្នាក់អគ្គនាយកដ្ឋាន និងថ្នាក់ស្មើ បានរៀបចំកិច្ចប្រជុំពិនិត្យលើការអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ របស់អង្គភាពចំណុះប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការបញ្ជ្រាបយេនឌ័រ ចំនុចជាវិជ្ជមាន និងចំនុចអវិជ្ជមាន បញ្ហាប្រឈម មូលហេតុ ពិភាក្សារកវិធានការអនុវត្តបន្ត ។ ក្រុមការងារយេនឌ័រ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ មានផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រាប់ជាយន្តការអនុវត្ត ។

**៣.២. ក្រុមការងារយេនឌ័រថ្នាក់រាជធានី-ខេត្ត** បានចូលរួមកិច្ចប្រជុំពិនិត្យលើការអនុវត្តបញ្ជ្រាបយេនឌ័រ តាមវិស័យជាមួយ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ រាជធានី ខេត្ត និងបានសហការចុះពិនិត្យសកម្មភាពតាមបណ្តាស្រុក ឃុំ សង្កាត់ គោលដៅ ។

## III. **ការសន្និដ្ឋាន**

ការអនុវត្តគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួង បានធ្វើឲ្យមានការសម្របសម្រួល ជាបណ្តើរៗទាំងទស្សនៈ ផ្នត់គំនិត ឥរិយាបថ ការរើសអើង អាកប្បកិរិយាទៅជាការទទួលស្គាល់នូវសារសំខាន់នៃ តួនាទីរបស់ស្ត្រី និងបានយកចិត្តទុកដាក់ បំប៉នសមត្ថភាពបង្កឱកាសបានបំពេញការងារ ការតែងតាំង តម្លើងឋានៈ និងរៀបឋានន្តរសក្តិ សមស្របតាមសមត្ថភាព ។

នៅថ្នាក់ក្រោមជាតិ ការអនុវត្តកម្មវិធី សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ការអនុវត្តកំណែទម្រង់ បានធ្វើឲ្យស្ត្រី មានតួនាទីដ៏សំខាន់ក្នុងការដឹកនាំ មានសេចក្តីក្លាហាន បញ្ចេញយោបល់ក្នុងការធ្វើសេចក្តីសម្រេចគ្រប់កម្រិត ហើយមានចំនួនកើនឡើង ។ ប្រជាពលរដ្ឋសំខាន់បងប្អូនស្ត្រី ទទួលបានឱកាសសមស្រប ក្នុងការចូលរួមកិច្ចអភិវឌ្ឍរបស់ មូលដ្ឋាន និងទទួលបានផលប្រយោជន៍ ដោយមិនរើសអើង ដោយសមធម៌ ពីការផ្តល់សាធារណៈនានា ។

**១. ចំណុចជាវិជ្ជមាន៖**

- ក្រសួងបានដាក់ចេញនូវវិធានការដាក់លាក់បញ្ជ្រាបយេនឌ័រ និងបានបង្កើនតួនាទីរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច ។
- សមភាពយេនឌ័រមានភាពប្រសើរស្ទើរគ្រប់ជំនាញ ចំនួនស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេចមានចំនួនកើនឡើង ។
- ស្ត្រីមានឱកាសពេញលេញក្នុងការទទួលការជ្រើសរើសក្របខ័ណ្ឌថ្មី ។ មន្ត្រីជាស្ត្រីសម្រាប់បន្តវេន ក៏មានចំនួនកើនដែរ ។
- មន្ត្រីជាស្ត្រីត្រូវបានគាំទ្រ និងបង្កលក្ខណៈបានអភិវឌ្ឍន៍សមត្ថភាពចំណេះដឹងទូទៅ ជំនាញ ទាំងក្នុង និងក្រៅប្រទេស ។
- ប្រជាពលរដ្ឋ សំខាន់បងប្អូនស្ត្រី ទទួលបានឱកាសសមស្រប ការចូលរួមកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងទទួលបានផលប្រយោជន៍ ដោយសមធម៌ ពីការផ្តល់សេវាសាធារណៈនានា ។

**២. បញ្ហាប្រឈម៖**

- សមត្ថភាពរបស់ក្រុមការងារយេនឌ័រ ក្នុងការវិភាគបញ្ហាយេនឌ័រ ការស្វែងរកការគាំទ្រមតិ និងការបញ្ជ្រាបទស្សនៈយេនឌ័រ នៅមានកម្រិត ។
- ការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៅក្នុងផែនការសកម្មភាព ឬ ការងារជំនាញមិនទាន់បានគ្រប់ជ្រុងជ្រោយ និងពុំសូវមានការត្រួតពិនិត្យ តាមដាន វាយតម្លៃ ទៅតាមតម្រូវការយេនឌ័រជាក់ស្តែង ។
- មន្ត្រីជាស្ត្រីភាគច្រើនស្ថិតនៅក្នុងមុខតំណែងទាបនៅគ្រប់វិស័យសាធារណៈ ជាពិសេសក្នុងមុខតំណែងគ្រប់គ្រងស្ត្រីភាគច្រើនជាប្រធាន ។
- ការលើកកម្ពស់សមភាពយេនឌ័រ ក្នុងតួនាទីធ្វើសេចក្តីសម្រេច នៅតែជាការទទួលខុសត្រូវ ដ៏ធំធេងរបស់ស្ត្រី ទោះបីការងារនេះ ជាការទទួលខុសត្រូវរួមគ្នារវាងស្ត្រី និងបុរសក៏ដោយ ។
- ស្ត្រី ខ្លួនឯងមិនសូវមានជំនឿលើសមត្ថភាព ភារកិច្ច ជំនាញ ។
- មិនទាន់មានភាពកិច្ចសហការ រវាងដៃគូ ពាក់ព័ន្ធ ។
- ការវិភាគថវិកាសម្រាប់គម្រោងកម្មវិធីយេនឌ័រនៅមានកម្រិត ។

**៣. មេរៀនពិសោធន៍**

- រាជរដ្ឋាភិបាលកម្ពុជា មានកម្មវិធីគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រជាតិដែលពាក់ព័ន្ធ លើការលើកកម្ពស់សមភាពយេនឌ័រ និង បង្កើនភាពអង់អាចដល់ស្ត្រី ។
- ក្រសួងមហាផ្ទៃមានផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងមានយន្តការសម្រាប់ក្រុមការងារយេនឌ័រ និងបណ្តាញក្រុមការងារយេនឌ័រ អនុវត្តទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។
- មានការសហការល្អ ផ្ទៃក្នុងក្រសួង និង ស្ថាប័ន អង្គការជាតិ - អង្គការអន្តរជាតិ ដែលពាក់ព័ន្ធ លើការអនុវត្តគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ ។

- ការប្តេជ្ញាចិត្ត របស់ថ្នាក់ដឹកនាំ ក្នុងការជំរុញអនុវត្ត ។
- មានការគាំទ្រ និង វិភាគថវិកាសម្រាប់កម្មវិធីយេនឌ័រ ។

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ ............. ឆ្នាំ២០១...

**រដ្ឋលេខាធិការ**

**ប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ**